**រដ្ឋបាលព្រៃឈើ**

គំរោងអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសពត៌មានស្តីពីការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ

ព្រៃឈើកម្ពុជា បានរងនូវការគំរាមកំហែងច្រើនយ៉ាង នៃការរិចរឹល និងប្រែក្លាយទៅជាការប្រើប្រាស់ផ្សេងៗទៀត ។ ដូច្នេះ គឺ ជាតំរូវការបន្ទាន់ ចាំបាច់ ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាព និង ប្រើប្រាស់ព្រៃឈើដោយសមធមិតាមរយៈក្របខ័ណ្ឌកម្មវិធីជាតិរយៈពេលវែងមួយ ។

នៅក្នុងកិច្ចប្រជុំ ***" វេទិការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា"*** នាពេលកន្លងទៅនេះ សហគមន៍អន្តរជាតិបាន សន្យាផ្តល់ជំនួយឧបត្ថម្ភបន្ថែមយ៉ាងច្រើន សន្ធឹកសន្ធាប់ ។ ប្រការនេះ បញ្ជាក់ឱ្យឃើញនូវការគាំទ្រ ដល់ការដឹកនាំ និងតួនាទី របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីចូលរួមចំណែក បង្កើនជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។

រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយនឹងភាគីពាក់ព័ន្ធបាននឹងកំពុងដំណើរការរៀបចំចងក្រងកម្មវិធីព្រៃឈើជាតិ សំដៅធ្វើយ៉ាងណាសំរេចឱ្យបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ កម្មវិធីព្រៃ ឈើជាតិឆ្លើយតបទៅនឹងតំរូវការថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិក្នុងការរៀបចំឱ្យមានកម្មវិធីគ្រប់គ្រងជាយុទ្ធសាស្ត្រ ដែលក្នុងដំណើរការនេះរួមមានទាំងការរៀបចំផែនការការគ្រប់គ្រង ការប្រើប្រាស់ ការការពារ និងការទាញយកផលប្រយោជន៍សំរាប់សង្គមនាពេលបច្ចុប្បន្ន និងអនាគត ។ កម្មវិធីព្រៃឈើជាតិនេះ កំពុងត្រូវបានរៀបចំឱ្យមានភាពស៊ីចង្វាក់ និង មានការគាំទ្រដល់ផែនការអភិវឌ្ឍន៍ជាតិ និងគោលដៅសហសវត្សន៍កម្ពុជា ។

ក្រុមការងារមួយ ដែលមានតំណាងពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជនត្រូវបានបង្កើតឡើង ដើម្បីរួមគ្នាចងក្រងកម្មវិធីនេះឱ្យក្លាយជាឯកសារគោលមួយដែលរួមមាន កម្មវិធីការងារជាអទិភាពចំនួនប្រាំមួយសំខាន់ៗ ។ កម្មវិធីការងារទាំងនោះរួមមាន ១. កម្មវិធីកំណត់ព្រំប្រទល់ដែនព្រៃឈើ ២. កម្មវិធី គ្រប់គ្រង និងអភិរក្សព្រៃឈើ ៣. កម្មវិធីពង្រឹងការអនុវត្តច្បាប់ និង អភិបាលកិច្ច ៤. កម្មវិធីសហគមន៍ព្រៃឈើ ៥. កម្មវិធីកសាងសមត្ថភាព និងស្រាវជ្រាវ និង ៦. កម្មវិធីវិនិយោគទុន ។ ការពិគ្រោះយោបល់ជាសាធារណៈលើពង្រាងឯកសារទាំងនេះនឹងត្រូវធ្វើឡើងក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ ។

ការចងក្រងកម្មវិធីព្រៃឈើជាតិនឹងត្រូវបញ្ចប់ជាស្ថាពរនៅខែកញ្ញា ឆ្នាំ២០០៩ ខាងមុខនេះដូចដែលមានកំណត់ក្នុងតារាងសូចនាករតាមដានរួម របស់ ***វេទិកាសហប្រតិបត្តិអភិវឌ្ឍន៍កម្ពុជា*** ។ ដំណើរចងក្រងនេះ បានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍សំខាន់ៗដែលក្នុងនោះរួមមាន Danida, Dfid, FAO, UNDP, Jica និង WB ។

ប្រសិនបើមានមតិ ឬសំណូមពរផ្សេងៗសូមផ្ញើទៅកាន់រដ្ឋបាលព្រៃឈើ ដែលមានអាស័យដ្ឋានអាគារលេខ ៤០ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ដោយសរសេរដាក់ថា ***" កម្មវិធីព្រៃឈើជាតិ"*** ។



រូបភាព ១ : សម្បត្តិព្រៃឈើ របស់ប្រទេសកម្ពុជា



រូបភាព២ : កិច្ចប្រជុំក្រុមការងារកម្មវិធីព្រៃឈើជាតិ